# ការសំភាសន៍របស់អ៊ុំប្រុស ប៊ុក សួន

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ ប៊ុក សួន

## <u>ការសង្ខេបប្រវត្តិរបស់អ៊ុំប្រុស ប៊ុក សួន</u>

អ៊ុំប្រុស ប៊ុក សួន មានអាយុ66ឆ្នាំ នៅឆ្នាំ2018។អ៊ុំប្រុស ប៊ុក សួន មានភេទប្រុស។អ៊ុំប្រុស ប៊ុក សួន មានទីលំនៅបច្ចុប្បន្ននៅ ភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ចឹងចាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍នេះត្រូវបានរៀបចុះឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិច ដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងដូចតា ហើយនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ បាទបានតា

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍អ៊ុំ គឺនៅថ្ងៃទី8 ខែ2 ឆ្នាំ2018 ចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំមានឈ្មោះធីគេដែរអ៊ុំ?

ខៈ ខ្ញុំឈ្មោះ សួន

កៈ ឈ្មោះអីគេសួនដែរអ៊ុំ?

ខៈ ឈ្មោះ ប៊ុល សួន

កៈ ចុះអ៊ុំមានឈ្មោះហៅក្រៅទេ?

ខៈ អត់មានទេ

កៈ ចុះកាលពីក្មេងធ្លាប់មាននរណាគេហៅឈ្មោះអ៊ុំអីផ្សេងទេ?

ខៈ អត់មានទេហៅតែឈ្មោះចឹងតែម្ដងនឹង

កៈ ចុះអ៊ុំសព្វថ្ងៃអ៊ុំមានអាយុប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំមានអាយុ66ឆ្នាំ

កៈ អ៊ុំអាយុ66ឆ្នាំ ចុះអ៊ុំមានដឹងថាអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខៈ នៅឆ្នាំ1953

កៈ នៅឆ្នាំ1953 ចុះខែអីគេអ៊ុំមានចងចាំទេ?

ខៈ អត់ចាំទេភ្លេចអស់ហើយនឹងហាស

កៈ ចុះអ៊ុំកើតនៅឆ្នាំអីគេដែរអ៊ុំ លក្ខណៈជូត ឆ្លូវ ខាល ថោះហាស?

ខៈ ខ្ញុំឆ្នាំមមី

កៈ អូ៎!អ៊ុំឆ្នាំមមីហោសអ៊ុំ ចុះអ៊ុំកើតនៅណាដែរអ៊ុំមានចងចាំទេ?

ខៈ ខ្ញុំកើតនៅភូមិព្រៃឈើទាល

កៈ កើតនៅភូមិព្រៃឈើទាល ចុះឃុំអីគេដែរអ៊ុំ?

ខៈ ឃុំព្រៃគគី

កៈ ឃុំព្រៃគគី ស្រុកអីគេដែរអ៊ុំ?

ខៈ នៅស្រុកស្វាយទាប ខេត្តស្វាយរៀង

កៈ នៅស្រុកស្វាយទាប មិនមែនស្រុកស្វាយជ្រុំទេហោសអ៊ុំ?

ខៈ មិនមែនទេ ស្រុកស្វាយទាប ខេត្តស្វាយរៀង

កៈ ចុះអ៊ុំមានចងចាំថាបងប្អូនរបស់អ៊ុំមានប៉ុន្មាននាក់ដែរទេអ៊ុំ?

ខៈ បងប្អូនរបស់ខ្ញុំមាន5-6នាក់ដែរនឹង

កៈ ចុះមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរអ៊ុំមានចងចាំទេ?

ខៈ ចងចាំតា មានប្រុស2នាក់ នឹងស្រី4នាក់

កៈ មានស្រី2នាក់ ប្រុស4នាក់ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនទី3

កៈ ចុះអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេអ៊ុំ មានចងចាំឈ្មោះពួកគាត់ដែរទេ?

ខ៖  ខ្ញុំចាំខ្លះអត់ខ្លះដែរ

ក៖  អ៎ូ!អ៊ុំអាចរៀបរាប់ឈ្មោះនរណាគេដែរអ៊ុំចងចាំចឹងហាសអ៊ុំ?

ខ៖  លំអង គាត់ស្លាប់បាត់ហើយ ស្លាប់នៅពេលជំនាន់ពលពត

ក៖  ចុះបន្ទាប់មកទៀតអ៊ុំ?

ខ៖  ឈ្មោះយាន, ឈ្មោះ សោន ទាំងអស់5នាក់

ក៖  ប៉ុន្តែដូចជាស្លាប់ប៉ុន្មាននាក់ដែរទៅអ៊ុំ?

ខ៖  ស្លាប់មួយនាក់

ក៖  ម្នាក់ដែរបងធំគេហោសអ៊ុំ?

ខ៖  ស្លាប់បងទី2 ខ្ញុំទី3

ក៖  ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីជាមួយពយកគាត់ដែរហាស ដូចជាលេងឡឹកបាយឡ រឺមួយក៏លេងថុយ លេងកូនបែង រឺមួយក៏លេងអីចឹងហាសអ៊ុំ?

ខ៖  ខ្ញុំដែរលេងតា

ក៖  អ៊ុំលេងហោស អ៊ុំលេងអីគេខ្លះដែរអ៊ុំអាចប្រាប់ខ្ញុំបានទេអ៊ុំ?

ខ៖  លេងទាត់បាល់ លេងប៉ែង លេងអុក លេងអីចឹងហាស

ក៖  លេងអុកដែរហោសអ៊ុំ អូអ៊ុំចេះលេងអុកដែរហោសអ៊ុំ?

ខ៖  បាទចេះតា

ក៖  ចុះអ៊ុំមានធ្លាប់លេងបិទពួន លេងគប់ឈូសអីទេអ៊ុំ?

ខ៖  លេងៗលេងគប់ឈូសអីលេងទាំងអស់នឹង

ក៖  ចុះអ៊ុំមានធ្លាប់លេងបាញ់ឃ្លី លេងអីទេអ៊ុំ?

ខ៖  លេងដែរតា

ក៖  អ៎ូ!កាលពីជំនាន់អ៊ុំនឹងមានលេង បាញ់ឃ្លី លេងគប់ឈូស រឺមួយលេងគប់ក្រដាសអីនឹងហោសអ៊ុំមានបាលេងទេ?

ខ៖  បាទៗៗមានលេងតា លេងបិទពួន ប៉ុន្តែគប់ក្រដាសខ្ញុំមិនសូវចំណូលទេ ពេលដែរឃ្វាលក្របីខ្ញុំលេងតែប៉ែងនឹង

កៈ អូ!ពេលដែរឃ្វាលក្របីអ៊ុំលេងតែកូនប៉ែងទេណាអ៊ុំ?

ខៈ បាទលេងតែចឹង

កៈ ចុះនៅស្រែអ៊ុំមានធ្លាប់លេងអីទៀតជាមួយបងប្អូនរបស់អ៊ុំ?

ខៈ លេងទាត់បាល់

កៈ លេងទាត់បាល់ណាអ៊ុំ?

ខៈ នឹងហើយនឹងដើរលេងអីចឹងទៅ

កៈ ចុះអ៊ុំចូលចិត្តលេងអីគេដែរអ៊ុំកាលពីអ៊ុំនៅក្មេងៗហាសអ៊ុំ?

ខៈ ចូលចិត្តលេងបាយឡឹកបាយឡ

កៈ ចូលចិត្តលេងបាយឡឹកបាយឡហោសអ៊ុំ?

ខៈ លេងតែចឹងឯង

កៈ អូ!បាទអ៊ុំ ចុះបងប្អូនរបស់អ៊ុំសព្វថ្ងៃនឹងគាត់រស់នៅណាដែរអ៊ុំ?

ខៈ នៅនឹង2នាក់ មាន2នាក់នៅស្រែដែរនឹងហាស

កៈ នៅភ្នំពេញ2នាក់ នឹងនៅស្រែ2នាក់ដែរ ចុះនៅភ្នំពេញគាត់ធ្វើអីគេដែរអ៊ុំ?

ខៈ រកស៊ីលក់ដូរបន្តិចបន្តួចទៅ

កៈ ចុះអ្នកនៅស្រែពួកគាត់ធ្វើអីគេដែរអ៊ុំ?

ខៈ នៅស្រែគាត់ធ្វើស្រែនឹង

កៈ ទាំងពីរនាក់គាត់ធ្វើស្រែទាំងពីរនាក់ហោសអ៊ុំ?

ខៈ នឹងហើយនៅពីរនាក់នឹង

កៈ ប៉ុន្តែឪពុកវិញ?

ខៈ ឪពុកបានស្លាប់អស់ហើយនឹង

កៈ ចុះគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់ឈ្មោះ សាន្ត

កៈ ចុះឪពុកអ៊ុំគាត់អាយុប៉ុន្មានដែរអ៊ុំ?

ខ៖ គាត់ស្លាប់នឹងអាយុ60ឆ្នាំ

ក៖ ប៉ុន្តែគាត់ស្លាប់ប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖ គាត់ស្លាប់នឹងអស់រយះពេល5-6ឆ្នាំហើយនឹង

ក៖ អស់រយះពេល6ឆ្នាំណាអ៊ុំ?

ខ៖ នឹងហើយទាំងម្ដាយទាំងអីនឹងហាស

ក៖ ឪពុករបស់អ៊ុំហាសស្លាប់ឆ្នាំណាដែរ?

ខ៖ ឪពុករបស់ខ្ញុំគាត់ស្លាប់កាលពីបែកអាពតហាស អសរយះពេល1-2ឆ្នាំនឹងគាត់ស្លាប់បាត់ទៅនឹងហាស

ក៖ ចឹងមានន័យថាដូចជាគាត់អាយុចូល92-93ឆ្នាំហើយអ៊ុំ?

ខ៖ ជំនាន់សម្ដេចនឹង

ក៖ គាត់កើតជំនាន់សម្ដេចហោសអ៊ុំ?

ខ៖ ខ្ញុំស្គាល់ដែរតា

ក៖ ចឹងមានន័យថាគាត់កើតនៅឆ្នាំមួយពាន់ប្រាំបួនរយម្ភៃជាងណាអ៊ុំ?

ខ៖ ប្រហែលជាប៉ុណ្ណឹងហើយ

ក៖ ចុះគាត់កើតនៅណាអ៊ុំមានដឹងទេ?

ខ៖ គាត់កើតនៅភូមិព្រៃឈើទាល ឃុំគគី

ក៖ ចុះម្ដាយរបស់អ៊ុំវិញ?
ខ៖ ម្ដាយក៏គាត់កើតនៅណុងដែរ?

ក៖ ប៉ុន្តែម្ដាយរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ កាត់មានឈ្មោះពុត អឹម

ក៖ គាត់ឈ្មោះពុត អឹម គាត់អាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ពូកគាត់អាយុប្រហាក់ប្រហែលគ្នា

ក៖ ចឹងមានន័យថាគាត់កើតនៅឆ្នាំ1920ឆ្នាំជាងដូចគ្នាមែនទេអ៊ុំ?

ខ៖ នឹងហើយប៉ុណ្ណឹង

កៈ ចុះឪពុករបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ គាត់ធ្វើស្រែនឹង

កៈ ចឹងគាត់ធ្វើតែស្រែទេណាអ៊ុំ?

ខៈ បាទកាត់ធ្វើតែស្រែទេ មុនជំនាន់ពលពតគាត់ធ្វើតែស្រែទេ

កៈ ប៉ុន្តែគាត់មានធ្លាប់លក់ដូរ រឺមួយក៏ធ្លាប់រកស៊ីអីទេអ៊ុំ?

ខៈ អត់ដែរទេ

កៈ អត់ទេហោសអ៊ុំ ចុះគាត់ជាមនុស្សយ៉ាងម៉េចដែរអ៊ុំ គាត់ស្លូត រឺមួយក៏កាចដែរអ៊ុំ?

ខៈ គាត់ស្លូតណាស់

កៈ អូ៎!គាត់ស្លូតណាអ៊ុំ?

ខៈ ឪពុករបស់ខ្ញុំគាត់ស្លូតណាស់ម្តាយរបស់ខ្ញុំក៏ចឹងដែរ?

កៈ ម្តាយរបស់អ៊ុំគាត់ស្លូតដែរ ចុះម្តាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ ធ្វើស្រែដូចតែគ្នា ជាមួយឪពុកដែរនឹង

កៈ ចុះអ៊ុំមានចងចាំថាពេលដែរកាលអ៊ុំនៅជាមួយឪពុកម្តាយរបស់អ៊ុំ អ៊ុំមានធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់ដែរទេ?

ខៈ ឃ្វាលក្របី ធ្វើស្រែ

កៈ អូ៎!ឃ្វាលក្របី ភ្ជួរស្រែហោសអ៊ុំ?

ខៈ មានបរទេះដឹកស្រូវអីនឹងហាស

កៈ បាទមានអីផ្សេងទៀតអត់អ៊ុំ?

ខៈ អត់មានអីទៀតទេ

កៈ ចុះម្តាយរបស់អ៊ុំគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំទេ?

ខៈ មិនដែរទេ

កៈ ថាកាលពីគាត់នៅតូចៗ គាត់ធ្លាប់ធ្វើអីគេខ្លះ ហើយនឹងគាត់ក្រមុំគាត់ធ្លាប់ធ្វើអីគេខ្លះដែរចឹងហាសអ៊ុំ មានដែរទេអ៊ុំ?

ខៈ គាត់ប្រាប់ដែរប៉ុន្តែភ្លេចអស់ហើយនឹង

កៈ អូ៎!ភ្លេចហោសអ៊ុំ ?

ខៈ ចុះយើងអាយុច្រើនដែរហើយនឹង

កៈ ចុះឪពុករបស់អ៊ុំវិញ គាត់ធ្លាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខៈ ដូចគ្នាចឹងសុទ្ធតែភ្លេចអស់ហើយគាត់ប្រាប់ដែរប៉ុន្តែមិនសូវចាំទេ ទល់ឥឡូវនឹងភ្លេចអស់ហើយនឹងហាស

កៈ បាទអ៊ុំ ចុះយាយតាខាងឪពុកអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេអ៊ុំ?

ខៈ អត់ស្គាល់ទេ

កៈ អត់ស្គាល់ទេណា ចុះយាយតាខាងម្តាយអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ស្គាល់ខ្លះដែរ

កៈ ចុះគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់ឈ្មោះឈិន

កៈ ចុះយាយវិញអ៊ុំ?
ខៈ យាយឈ្មោះ ស្រីម៉ៅ

កៈ ចុះយាយតាទាំងខាងឪពុក នឹងទាំងខាងម្តាយអ៊ុំមានចងចាំថាគាត់អាយុប៉ុន្មានដែរទេ?

ខៈ គាត់ស្លាប់នៅជំនាន់ពលពត ស្លាប់រឿងអត់បាយតែម្តងនឹង

កៈ ចុះគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខៈ គាត់កើតនៅណុងនៅស្រុកភូមិជាមួយគ្នានឹង

កៈ ទាំងយាយទាំងតាតែម្តងហោសអ៊ុំ?

ខៈ នឹងហើយទាំងយាយ ទាំងតានឹងកើតនៅណុង

កៈ ចុះអ៊ុំមកនៅភ្នំពេញនឹងយូរនៅអ៊ុំ?

ខៈ ពេលដែរជំលាសពីអាពតវិញនឹង មកនៅភ្នមពេញតែម្តងនឹង យូរដែរហើយនឹងហាស

កៈ ប្រហែលជាប៉ុន្មានឆ្នាំដែរអ៊ុំ?

ខៈ វាយូរដែរនឹង ច្រើនឆ្នាំហើយ

កៈ វាប្រហែលជា30-40ឆ្នាំហើយណាអ៊ុំ?

ខ៖  ប្រហែលជាប៉ុណ្ណឹង

ក៖  ចុះអ៊ុំមានបងប្អូន រឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសដែរអ៊ុំ?

ខ៖  មានតែក្មួយបងប្អូនស្រី

ក៖  គាត់នៅណាដែរអ៊ុំ?

ខ៖  គាត់រស់នៅអាមេរិច

ក៖  អូ៎!គាត់រស់នៅអាមេរិចហោសអ៊ុំ ប៉ុន្តែគាត់ធ្វើអីគេនៅណុងអ៊ុំមានដឹងអត់?

ខ៖  អត់ដឹងដែរមិនដឹងថាគាត់ធ្វើអីផងនឹង

ក៖  ប៉ុន្តែគាត់ធ្វើមកលេងខ្មែរទេ?

ខ៖  ធ្លាប់មកលេងដែរតា

ក៖  ធ្លាប់មកលេងអ៊ុំទេ?

ខ៖  ធ្លាប់បានមកពីរទៅបីដងដែរនឹង

ក៖  ប៉ុន្តែគាត់រស់នៅរដ្ឋណាអ៊ុំអត់ដឹងទេហោសអ៊ុំ?

ខ៖  ដឹងតែគាត់នៅអាមេរិច

ក៖  ដឹងតែគាត់រសនៅអាមេរិចហោស ចុះភរិយារបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ឈ្មោះពុត សាន់

ក៖  ចុះអ៊ុំមានចងចាំថាអ៊ុំការនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖  ការនៅជំនាន់ពលពត

ក៖  នៅជំនាន់ពលពត នៅដាច់ពលពត រឺ មុនពលពត រឺពាក់កណ្តាលពលពតដែរអ៊ុំ?

ខ៖  នៅពលពតនឹង

ក៖  នៅជំនាន់ពលពតនឹងតែម្តងហោស
ចឹងមានន័យថាអ៊ុំការរស់ប្រហែលជា40ឆ្នាំជាងហើយណាអ៊ុំ?

ខ៖  បាទនឹងហើយ

ក៖  ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងនរណាគេជាអ្នករៀបចំអោយអ៊ុំដែរ?

ខ៖ ប្រធានពលពតនឹង

ក៖ អ៊ូ!ប្រធានពលពតចាប់អាអ៊ុំរៀបការតែម្ដងហោសអ៊ុំ?

ខ៖ នឹងហើយចាប់រៀបគូរតែម្ដងនឹង ជំនាន់ខ្ញុំរៀបអាពាហ៍ពិពាហ៍នឹងប្រហែលជា50-60គូរណោះច្រើនណាស់

ក៖ មាន60គូរប៉ុន្តែអ៊ុំរៀបនៅណាដែរអ៊ុំ ?

ខ៖ រៀបនៅស្អីទេនេះ.........

ក៖ អ៊ុំរៀបនៅខេត្តណាដែរអ៊ុំ?

ខ៖ ខេត្តមកនៅលើៗនេះ មិនសូវស្គាល់ដែរភ្លេចបាត់អស់ហើយនឹងហាស

ក៖ ប៉ុន្តែពេលណុងអត់មានថ្លៃទឹកដោះ រឺមួយថ្លៃជំនូនអីទេហោសអ៊ុំ?

ខ៖ អត់មានទេ

ក៖ ប៉ុន្តែពេលណុងយើងមិនដឹងថាយើងស្រលាញ់គ្នាអី យើងអត់ដឹងទេ ទៅដល់ចាប់យកតែម្ដងហោសអ៊ុំ?

ខ៖ បាទមិនសូវស្រលាញ់ដែរនឹងហាស ដល់ហើយគេចាប់គូរអោយតែម្ដងនឹង

ក៖ ប៉ុន្តែអ៊ុំធ្លាប់ឃើញអ៊ុំស្រីពីមុនទេ?

ខ៖ អ៊ុំស្រីពីមុននឹងនៅភូមិជាមួយគ្នានឹង

ក៖ ចឹងមានន័យថាយើងធ្លាប់ឃើញគ្នាហើយណាអ៊ុំ?

ខ៖ បាទធ្លាប់ឃើញគ្នាពីមុនហើយនឹង

ក៖ ប៉ុន្តែគ្រាន់តែពលពតចាប់យក នឹងលក្ខណៈយ៉ាងម៉េចអ៊ុំអាចរៀបរាប់បានខ្លះៗដែរទេអ៊ុំ ថាហេតុអីបានគេចាប់អោយយើងការជាមួយម្នាក់នឹងអីចឹងហាស?

ខ៖ ពីមុនខ្ញុំស្រលាញ់គ្នាដែរនឹង ហើយគេចាប់ការអោយនឹង

ក៖ យើងសុំគេការជាមួយម្នាក់នឹងតែម្ដង រឺមួយក៏អត់ទេអ៊ុំ?

ខ៖ ខ្ញុំស្រលាញ់គ្នាតិចៗដែរនឹង ហើយគេចាប់គូររៀបអោយតែម្ដងនឹងហាស

ក៖ ប៉ុន្តែបើគេចាប់អោយយើងការជាមួយអ្នកផ្សេង ក៏យើងអត់មានសិទ្ធិដើម្បីបដិសេធដែរមែនទេអ៊ុំ?

ខ៖  បាទត្រូវហើយនឹង

ក៖
ប៉ុន្តែហេតុអីបានជំនាន់ពលពតគេចាប់អោយយើងការចំមនុស្សយើងស្រលាញ់ចឹងហាសមួយនឹងលក្ខណះយ៉ាងម៉េចដែរអ៊ុំ?

ខ៖  ពលពតគេរៀបអោយនឹង រៀបអោយត្រូវគូរតែម្តងនឹង

ក៖  ចុះអ្នកដែរការផ្សេងពួកគាត់ម៉េចទៅអ៊ុំ?

ខ៖  អ្នកខ្លះទៅមិនស្រលាញ់គ្នា អ្នកខ្លះទៅស្រលាញ់គ្នាចឹងទៅ
ហើយពេលដែរជំលាសមិនវិញនឹងលែងគ្នារហូតដែរនឹង ដោយសារតែអត់ស្រលាញ់គ្នាចឹងលែងគ្នារហូតដែរនឹង

ក៖  ដោយសារតែពួកគាត់អត់ស្រលាញ់គ្នា រឺមកពីអីហើយណាអ៊ុំ?

ខ៖  អត់ដឹងថាហេតុអីបានជាគេលែងគ្នា

ក៖  ចុះអ៊ុំមានចេះភាសាខ្មែរទេអ៊ុំ ធ្លាប់បានរៀនទេអ៊ុំ?

ខ៖  ធ្លាប់បានរៀនខ្លះដែរនឹង អាចមើលអក្សរបានដែរនឹង

ក៖  រៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖  រៀនបានថ្នាក់ទី9

ក៖  អូ្!អ៊ុំរៀនបានថ្នាក់ទី9 ចុះកាលពីអ៊ុំរៀននឹងតើអ៊ុំរៀននៅណាដែរអ៊ុំ?

ខ៖  រៀននៅសាលាព្រៃគគី

ក៖  រៀននៅព្រៃគគីហោសអ៊ុំ ឈ្មោះសាលាឈ្មោះចឹងតែម្តងហោសអ៊ុំ?

ខ៖  បាទ រៀននៅសាលាព្រៃគគីនឹង

ក៖  ចុះអ៊ុំធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាដែរអត់អ៊ុំ?

ខ៖  មានដែរតា

ក៖  គាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ឈ្មោះគីនដ៉ា នៅច្បារអំពៅ

ក៖  ចុះមានឈ្មោះអីផ្សេងទៀតអត់អ៊ុំ?

ខ៖  មានតែមួយនឹង

ក៖  ចឹងមានតែមួយនឹងទេណាអុំ ដែរមិត្តភក្តិស្និទ្ធិស្នាលតែម្តងនឹង?

ខ៖  បាទមានតែមួយនឹងឯង

ក៖  ចុះអុំ មានចងចាំអនុស្សាវរីយ៍អីជាមួយមិត្តភក្តិរបស់អុំទេ?

ខ៖  មានតាលីសែងអីជាមួយគ្នានឹង

ក៖  នឹងកាលពីជំនាន់ពលពតណោះអុំ?

ខ៖  អត់ទេបែកពីអាពតមកវិញហើយនឹងហាស

ក៖  ចុះឥឡូវនឹងគាត់នៅណាដែរទៅអុំ?

ខ៖  នៅណុង នៅច្បារអំពៅនឹង

ក៖  ប៉ុន្តែប៉ុន្មានថ្ងៃអុំទៅលេងគ្នាម្តងហោសអុំ?

ខ៖  មិនដែរបានទៅទេ

ក៖  យើងរវល់រៀងខ្លួនណាអុំ?

ខ៖  យើងរវល់ពេក យើងរវល់រកស៊ីយើងខ្វះខាតហាស

ក៖  ខាងគេក៏មិនសូវបានមកលេងដែរ?

ខ៖  ខាងគេក៏មិនសូវបានមកលេងដែរ ខាងគេនឹងធ្វើចូ្ផា

ក៖  ចុះអុំស្គាល់គ្នាតាំងពីតូចៗរឺមួយក៏អុំស្គាល់គ្នាពេលដែរពលពតដែរអុំ?

ខ៖  ទើបតែស្គាល់ឥឡូវនឹងៗដែរនឹង

ក៖  ចុះកាលពីអុំនៅតូចៗនឹង អុំធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរអត់អុំ?

ខ៖  មានដែរប៉ុន្តែគាត់ស្លាប់បាត់អស់ហើយនឹង

ក៖  ប៉ុន្តែពួកគាត់មានឈ្មោះអីគេខ្លះដែរអុំមានចងចាំឈ្មោះទាំងអស់ទេ?

ខ៖  ចាំតា

ក៖  ប៉ុន្តែពួកគាត់ឈ្មោះអីគេខ្លះដែរទៅ?

ខ៖  ឈ្មោះកិន, ទយ ,ខន មានស្អីៗគេខ្លះទេភ្លេចអស់ហើយនឹងហាស ខ្ញុំមិនសូវចាំដែរទេ?

កៈ ចុះអ៊ុំមានចងចាំថាអ៊ុំធ្លាប់ធ្វើអីជាមួយពួកគាត់ដែរទេអ៊ុំ?

ខៈ ឧស្សាហ៍ទាត់បាល់ជាមួយគ្នា

កៈ អូ៎!អ៊ុំឧស្សាហ៍ទាត់បាល់ហោសអ៊ុំ?

ខៈ លេងទាត់បាល់ លេងបិទពួន លេងគប់កៅស៊ូ លេងគប់ស្អីៗនឹងហាស

កៈ ចុះធ្លាប់ទៅស្រែលេងអីជាមួយគាត់ដែរទេអ៊ុំ?

ខៈ បាទលេងដែរតា

កៈ ចុះទៅស្រែលេងអីគេខ្លះជាមួយមិត្តភក្តិរបស់អ៊ុំហាស?

ខៈ លេងប៉េងអីនឹង

កៈ អូ៎!លេងប៉េងហោសអ៊ុំ?

ខៈ ទៅឃ្វាលគោ ជាមួយគ្នា ដេញចាប់ចាបអីនឹង ពេលភ្លៀងនឹងដេញចាប់ចាបជាមួយគ្នា ដេញលលក ដេញក្រួចអីនឹងហាស

កៈ អូ៎!សប្បាយណាស់ណាអ៊ុំ?

ខៈ ពេលណុងសប្បាយណាស់

កៈ ចុះធ្លាប់ចាប់ត្រីចាប់ក្តាមអីនឹងដែរហោសអ៊ុំ?

ខៈ នឹងហើយធ្លាប់ដែរនឹង ចាប់ក្តាមនៅបឹង

កៈ ប៉ុន្តែពេលណុង យើងនៅអាយុស្គរៗគ្នាទេមែនទេអ៊ុំ?

ខៈ យើងនៅអាយុស្គរៗគ្នានឹងហាស ជួនកាលទៅបងមួយឆ្នាំទៅពីរឆ្នាំអីនឹងហាស ជួនកាលខ្ញុំបងគេមួយឆ្នាំទៅពីរឆ្នាំចឹងដែរនឹង

កៈ ចុះអ៊ុំមានធ្លាប់ធ្វើការងារអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខៈ ខ្ញុំធ្វើតែស្រែនឹង ហើយមកនេះគ្មានធ្វើអីទេរកស៊ីនឹងតិចតួច

កៈ បាទអ៊ុំ ចឹងអ៊ុំធ្លាប់ទៅធ្វើនៅវាលស្រែមែនទេអ៊ុំ?

ខៈ ធ្លាប់ធ្វើ

កៈ អ៊ុំធ្លាប់ធ្វើអីគេនៅណុង ពេលដែរអ៊ុំធ្វើហាស?

ខៈ ធ្វើចំការដាំស្ពៃដាំអីនឹង

កៈ  អ៊ុំ!ដាំស្ពៃណាអ៊ុំ?

ខៈ  ដាំស្ពៃ សាឡាត់ ខាត់ណា ស្ពៃក្តោបអីនឹង

កៈ  ចុះនៅស្រែអ៊ុំធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខៈ  នៅស្រែធ្វើតែស្រែនឹង

កៈ  ធ្លាប់ដកស្ទូង ច្រូតកាត់ ហើយនឹងព្រុះអីណាអ៊ុំ ?

ខៈ  ដក ស្ទូង ច្រូតកាត់អីនឹង

កៈ  ពេលខ្លះអ៊ុំនឹងភ្ជួររាស់អីដែរណាអ៊ុំ?

ខៈ  នឹងហើយមានភ្ជួររាស់ដែរ

កៈ  ចុះអ៊ុំធ្លាប់ធ្វើអាជីវកម្មនៅក្នុងក្រុមគ្រួសារដែរទេអ៊ុំ?

ខៈ  អត់ដែរទេ

កៈ  អត់ដែរទេណាអ៊ុំ?

ខៈ  អត់ដែរមានធ្វើអីទេនឹង

កៈ  ចុះអ៊ុំធ្លាប់លក់ដូរមុខរបររកស៊ីអីទេអ៊ុំ?

ខៈ  មានលក់បន្តិចបន្តួចដែរនឹង ដូចជាលក់ផ្លែឈើ

កៈ  លក់ផ្លែឈើណាអ៊ុំ លក់អេតចាយ?

ខៈ  ឥឡូវនឹងលក់អេតចាយម្តងនឹង

កៈ  ប៉ុន្តែជាមុខរបររបស់អ៊ុំល្អដែរ?

ខៈ  បាទល្អតា

កៈ  ចុះកាលពីមុនអ៊ុំធ្លាប់មានចិញ្ចឹមសត្វទេ ចិញ្ចឹមមាន់ ទា ជ្រូកអីចឹងហាស?

ខៈ  ចិញ្ចឹមតាប៉ុន្តែពេលដែរមកនឹងវាបាត់ទៅ
ហើយនឹងស្លាប់បាត់អស់ទៅលែងចិញ្ចឹមហើយនឹង
ដោយសារតែខ្ញុំចាស់ហើយចឹងទៅលែចិញ្ចឹម

កៈ  បាទអ៊ុំពេលណុងអ៊ុំចិញ្ចឹមអីគេដែរអ៊ុំ?

ខៈ  ចិញ្ចឹមមាន់ ទា ឆ្កែ ជ្រូកអីនឹង

កៈ  អ៊ុំអត់ដែរចិញ្ចឹមគោ ក្របីទេណាអ៊ុំ?

ខៈ  ចិញ្ចឹមគោ ក្របីចិញ្ចឹមតា

កៈ  អូ៎!អ៊ុំធ្លាប់ចិញ្ចឹមដែរ ហោសអ៊ុំ ចិញ្ចឹមនៅស្រុកមែនអ៊ុំ?

ខៈ  ចិញ្ចឹមនៅស្រុកនឹង

កៈ  ប៉ុន្តែចិញ្ចឹមលក្ខណៈច្រើន រឺចិញ្ចឹមប៉ុន្មានដែរអ៊ុំ?

ខៈ  ចិញ្ចឹមលក្ខណៈ5-6ក្បាលអីនឹង

កៈ  អូ៎!ចិញ្ចឹមច្រើនដែរអ៊ុំ?

ខៈ  មិនសូវជាច្រើនទេ

កៈ  បាទ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំ
កាលពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខៈ  មានការផ្លាស់ប្តូរច្រើន

កៈ  មានការផ្លាស់ប្តូរអីគេខ្លះទៅអ៊ុំ?

ខៈ  ផ្លាស់ប្តូររកស៊ី

កៈ  មានការផ្លាស់ប្តូរអីផ្សេងទៀតអត់អ៊ុំ?

ខៈ  អត់មានទេ

កៈ  ចុះទាំងសុខភាព នឹងជីវភាពយ៉ាងម៉េចដែរអ៊ុំ?

ខៈ  សុខភាពមិនសូវជាឈឺទេឥឡូវនឹង ជីវភាពវិញបរបូរណ៍រឹងមាំ

កៈ  ចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខៈ  មានម្ហូបអីក៏ហូបដែរនឹង

កៈ  អូ៎!បាទអ៊ុំ ចុះម្ហូបដែរអ៊ុំចូលចិត្តតែម្តងមានស្អីគេដែរអ៊ុំ លក្ខណៈថា ឆា ចៀន ស្ងោរ ស្លម្ចូរ
ការីអីចឹងហាសអ៊ុំ?

ខៈ  អីក៏បានដែរខ្ញុំ

កៈ  អូ៎!បាទ ចុះល្បែងប្រជាប្រិយ៍អីដែរអ៊ុំចូលចិត្តលេងដែរអ៊ុំ?

ខៈ  ល្បែងលេងឈូង

កៈ  លេងចោលឈូងហោសអ៊ុំ ចុះទាញព្រាត់ លាក់កន្សែងអីអ៊ុំ?

ខៈ  ទាញព្រាត់ លាក់កន្សែងអីនឹងលេងទាំងអស់នឹង

កៈ  ចុះល្បែងឡើងរាំវិញអ៊ុំចេះទេ?

ខៈ  ចេះតែផឹកស្រវឹងបានឡើងរាំ

កៈ  អូ៎!ទាល់តែស្រវឹងបានឡើងរាំហោសអ៊ុំ?

ខៈ  នឹងហើយចេះតែរាំលេងនឹង

កៈ  បាទអ៊ុំ ចុះអ៊ុំមានចេះច្រៀងទេអ៊ុំ?

ខៈ  អត់ចេះទេ និយាយដោយស្មោះ ខ្ញុំមិនដែរច្រៀងណាមួយបទទេ

កៈ  បាទអ៊ុំ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀងទេ?

ខៈ  ខ្ញុំចូលចិត្តណាស់បទចំរៀង

កៈ  ចុះបទចំរៀងអីដែរអ៊ុំចូលចិត្តស្តាប់ដែរអ៊ុំ លក្ខណៈបងសម័យ រឺមួយបទបុរាណដែរអ៊ុំ?

ខៈ  បទសុិនសុីសាមុ៉តអីច្រៀងនឹង

កៈ  អូ៎!បាទអ៊ុំ លក្ខណៈបទបុរាណណអ៊ុំ?

ខៈ  បាទបទបុរាណ បទសម័យនឹង

កៈ  ចុះអ៊ុំមាននរណាគេម្នាក់នៅក្នុងផ្ទះរបស់អ៊ុំ ចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខៈ  អត់មានទេ

កៈ  អត់មានទេណអ៊ុំ លក្ខណៈភ្លេងពិណពាត់ ភ្លេងការអីក៏អត់មានដែរណអ៊ុំ?

ខៈ  អត់មានទេ

កៈ  ចុះផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ  ផ្ទះរបស់ខ្ញុំមានស្អីទេ

កៈ  អូ៎!ប៉ុន្តែផ្ទះរបស់អ៊ុំឥឡូវនឹងយ៉ាងម៉េចដែរអ៊ុំ?

ខៈ  ផ្ទះនឹងវាទ្រុឌទ្រោមអស់ដែរនឹងហាស

កៈ  ប៉ុន្តែផ្ទះមួយនឹងមែនទេអ៊ុំ?

ខ៖ ផ្ទះនៅរាល់ថ្ងៃនឹងហាស

ក៖ អូ!បាទអ៊ុំ ចុះនរណាគេជាអ្នកសាងសងផ្ទះមួយនឹងដែរអ៊ុំ?

ខ៖ ខ្ញុំនឹងហើយ

ក៖ អូ!អ៊ុំចេះសាងសងផ្ទះហោសអ៊ុំ?

ខ៖ ខ្ញុំមិនមែនសាងសងទេ ប៉ុន្តែខ្ញុំអោយគេធ្វើ

ក៖ ចឹងមានថាអ៊ុំអោយលុយទៅ ហើយជួលគេធ្វើទៅ?

ខ៖ បាទអោយលុយគេ ដើម្បីអោយគេធ្វើអោយ

ក៖
ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងពេលដែរសាងសងគេប្រើឧបករណ៍អីគេសំរាប់សាងសងទេអ៊ុំ?

ខ៖ មិនដឹងទេ

ក៖ ដូចលក្ខណះថាមានឈើ មានដែកគោល មានដែកកាប់ ដែកគាស់?

ខ៖ នឹងហើយអានឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំមានជំនាញអីដែរអ៊ុំគិតថាអ៊ុំចេះស្ទាត់ជំនាញដែរទេអ៊ុំ?

ខ៖ អត់មានទេ

ក៖ ដូចជាវេញវល្លិ៍ ក្រូស្ថុ ធ្វើអញ្ចូត?

ខ៖ អត់ចេះទាំងអស់នឹង

ក៖ អត់ចេះទេណាអ៊ុំ
ប៉ុន្តែឪពុកម្តាយរបស់អ៊ុំគាត់មានធ្លាប់មានបង្រៀនជំនាញអីទៅអ៊ុំដែរទេ?

ខ៖ អត់មានទេ

ក៖ ចឹងគាត់មិនដែរបានបង្រៀនអីទៅអ៊ុំទេ?

ខ៖ អត់ដែរសោះ

ក៖ ចុះអ៊ុំអាចប្រាប់ពីការលំបាកនៅក្នុងឆាកជីវិតរបស់អ៊ុំបានទេ?

ខ៖ ជីវិតរបសខ្ញុំវេទនាណាស់

ក៖ អ៊ុំ អាចប្រាប់ខ្ញុំខ្លះៗបានទេអ៊ុំ?

ខ៖ ខ្ញុំកាលពីតូចមានអីម៉ែដាក់ចោលនឹង ទុកខ្ញុំចោលគេយកទៅចិញ្ចឹមនឹង ហើយម៉ែដើរកាត់មុខកូនចឹងទៅកូនយំ ហើយក៏លើកអោយបៅក៏រស់ដល់ឥឡូវនឹង ជីវិតរបស់ខ្ញុំកំសត់ណាស់

ក៖ ចុះកាលពីជំនាន់ពលពតគេអោយអ៊ុំធ្វើអីគេដែរទៅអ៊ុំ?

ខ៖ មានឃ្វាលក្របីទាំងហ្វូង ឃ្វាលគោទាំងហ្វូងដែរនឹង

ក៖ ប៉ុន្តែពេលណុងគេអោយអ៊ុំជំលាសទៅណាដែរទៅអ៊ុំ?

ខ៖ គេអោយទៅបាតដំបងហោស

ក៖ អូ៎!អោយទៅខេត្តបាត់ដំបងហោស ចុះគេអោយអ៊ុំទៅតែខេត្តបាត់ដំបងមួយ រឺគេអោយអ៊ុំទៅខេត្តអីផ្សេងទៀតអ៊ុំ?

ខ៖ នៅតែណុង

ក៖ ប៉ុន្តែពេលណុងគេអោយអ៊ុំនៅតែមួយកន្លែង នៅតែមើលគោ មើលក្របីទេហោសអ៊ុំ?

ខ៖ នឹងហើយធ្វើតែចឹង

ក៖ ប៉ុន្តែអ៊ុំពេលណុងនៅប៉ុណ្ណាដែរអ៊ុំ?

ខ៖ ពេលណុងមានគ្រួសារហើយនឹង

ក៖ អូ៎!អ៊ុំមានគ្រួសារហើយហោសអ៊ុំ?

ខ៖ នឹងហើយទៅមើលគោ មើលក្របី

ក៖ ចុះគេអោយអ៊ុំទៅលក្ខណះជាគ្រួសារ រឺមួយក៏អ៊ុំទៅម្នាក់ឯងដែរអ៊ុំ?

ខ៖ គ្រួសារទៅដោយគ្រួសារ ខ្ញុំដោយខ្ញុំចឹងទៅ

ក៖ ចឹងប្រពន្ធរបស់អ៊ុំទៅកន្លែងផ្សេង?

ខ៖ គេទៅកន្លែងផ្សេងទៅកងផ្សេងណា ទៅកងច្រូតស្រូវ នឹងស្ទូងស្រូវ

ក៖ ចុះឪពុកម្តាយរបស់អ៊ុំពេលណុងគេអោយទៅណាដែរអ៊ុំ?

ខ៖ ទៅណុងទាំងអស់គ្នានឹងហាស

ក៖ អូ៎!គេដោយជំលាសអោយទៅបាត់ដំបងទាំងអស់គ្នាហោសអ៊ុំ?

ខ៖ បាទទៅណុងទាំងអស់នឹង គេអោយទៅខេត្តបាត់ដំបងទាំងអស់គ្នានឹងហាស

កៈ ចុះឪពុកម្ដាយរបស់អ៊ុំ នឹងបងប្អូនរបស់អ៊ុំគេអោយធ្វើអីគេដែរអ៊ុំ?

ខៈ ទៅស្ទូង ដក

កៈ ទៅដក ស្ទូង នឹងធ្វើអីទៀតទៅ?

ខៈ ទៅស្ទូង ដក ហើយនឹងជីកប្រឡាយ

កៈ ចុះរបបអាហារយ៉ាងម៉េចវិញទៅអ៊ុំ?

ខៈ របបបានតែមួយកំប៉ុងពីរនាក់ជូនកាល កន្លះកំប៉ុងចឹងទៅណាស់

កៈ អ៎ូ!មួយកំប៉ុងច្រើនហាសណាស់?

ខៈ បានច្រើនដែរនឹង ដោយសារតែយើងកំលាំងទី1 ហើយកំលាំងទី2កន្លះកំប៉ុងចឹងទៅ ទី3ចេះតែហែៗចឹងទៅ

កៈ ចេះតែតិចទៅៗ?

ខៈ នឹងហើយតិចទៅៗនឹង

កៈ ចុះអ៊ុំដូចជាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ុំ?

ខៈ វេទនាខ្លាំងតែម្ដងនឹង វាធ្វើបាបជូនកាលទៅដេញក្របីនៅបឹងចឹងទៅ ហើយពួកទាហ៊ានលុណនុលនឹងបានឃើញចឹងទៅដេញបាញ់ចឹងទៅ

កៈ អ៎ូ!គេដេញបាញ់យើង?

ខៈ នឹងហើយបាញ់រះៗខំលូនចង់ស្លាប់នឹងទំរាំតែផុតវាលែងបាញ់នឹង

កៈ បាទអ៊ុំ ដូចជាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយវិធីណាដែរអ៊ុំ?

ខៈ ទាហ៊ានខ្មែរបាញ់

កៈ ចុះកាលដាច់ជំនាន់ពលពតគេអោយអ៊ុំធ្វើអីគេដែរទៅ?

ខៈ ឃ្វាលគោ

កៈ ប៉ុន្តែដាច់ជំនាន់ពលពតហើយហាស គេអោយអ៊ុំធ្វើអីគេដែរ?

ខៈ ពេលដាច់ពលពតហើយបានមកវិញ មានអីរកស៊ីខ្លួនឯងនឹង រកស៊ីពីរនាក់ប្ដីប្រពន្ធចឹងទៅ

កៈ អ៎ូ!អ៊ុំរកស៊ីខ្លួនឯងហោសអ៊ុំ?

ខ៖  បាទរកស៊ីពេលណុង

ក៖  បាទរកស៊ីនឹងអ៊ុំមានការលំបាកអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំដែរទៅអ៊ុំ?

ខ៖  វេទនាណាស់ទៅរកនឹង ទៅចុះបឹង ដកខ្ទាវឈូក បេះព្រលិត បេះត្រកួនអីនឹង បេះត្រកួននៅបឹង បេះព្រលិតនៅបឹង

ក៖  ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាសប្បាយជាងគេនៅក្នុងជីវិតរបស់អ៊ុំដែរអ៊ុំ?

ខ៖  គ្មានសប្បាយទេកើតទុករហូតនឹង

ក៖  គ្មានពេលសប្បាយទេណអ៊ុំ?

ខ៖  សប្បាយទាល់តែស្រុកល្អបានសប្បាយកើត

ក៖  ចុះតាំងពីក្មេងហាស អ៊ុំធ្លាប់មានក្ដីស្រម៉ៃថាធំឡើងអុំចងធ្វើអីគេដែរទេអ៊ុំ?

ខ៖  ចង់តែរៀនតែមួយមុខនឹង ប៉ុន្តែរៀនមិនបានទេ

ក៖  ចុះអ៊ុំគិតថាកាលពីនៅតូចហាស ធ្លាប់គិតថាអ៊ុំពេលដែរធំឡើងអ៊ុំចង់ធ្វើជាទាហ៊ាន ចង់ធ្វើជាប៉ូលីស រឺមួយធ្វើពេទ្យអីទេ?

ខ៖  អត់មានទេ

ក៖

ចុះបើចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗអ៊ុំគិតថាចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរអ៊ុំ?

ខ៖  ផ្ដែផ្ដាំអោយខំរៀនធ្វើការងារបានធំៗ

ក៖  ចុះមានអីចង់ផ្ដែផ្ដាំទៀតទេអ៊ុំ?

ខ៖  អស់ហើយនឹងហាស

ក៖  ចឹងជាចុងក្រោយអ៊ុំខ្ញុំសូមអរគុណច្រើនដែរបានពិភាក្សាជាមួយខ្ញុំ ដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ ចឹងអរគុណច្រើនណាស់អ៊ុំ៕៕៕